ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០២៩ ១៨ បល.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា. ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាសម្រាប់បម្រើការងារនៅ ទីស្តីការក្រសួងរ៉ែនិង ថាមពល និង នៅតាមបណ្តាមន្ទីររ៉ែ និង ថាមពលរាជធានី-ខេត្ត សម្រាប់ឆ្នាំ២០១៨

ក្រសួងរ៉ែ និង ថាមពល មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និង មន្ត្រីជាប់កិច្ចសន្យា ដែលបម្រើការងារជូនក្រសួងរ៉ែ និង ថាមពលក្នុងឆ្នាំ២០១៧ ទាំងអស់ជ្រាបថា សម្រាប់ឆ្នាំ២០១៨ ខាងមុខនេះ ក្រសួងរ៉ែ និង ថាមពល ជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាចំនួន ២០០នាក់ ឱ្យចូលបម្រើការងារ នៅទីស្តីការក្រសួង និង នៅតាមបណ្តាមន្ទីររ៉ែ និង ថាមពលរាជធានី-ខេត្ត ដែលមានតម្រូវការតាមមុខតំណែងដូចខាងក្រោម៖

១. ជំនួយការថ្នាក់ដឹកនាំ
២. ជំនួយការអង្គភាព ដែលមានជំនាញ ឬ ចំណេះដឹងផ្នែករដ្ឋបាល សេដ្ឋកិច្ច-គណនេយ្យ នីតិសាស្ត្រ និងជំនាញផ្សេងៗពាក់ព័ន្ធនឹងវិស័យ រ៉ែ ថាមពល និងប្រេងកាត
៣. អ្នកធ្វើអនាម័យ អ្នកបើកបរ និងសន្តិសុខ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និង មន្ត្រីជាប់កិច្ចសន្យាដែលកំពុងបម្រើការងារ អញ្ជើញមកដាក់ពាក្យស្នើសុំ នៅនាយកដ្ឋានបុគ្គលិក ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ រៀងរាល់ថ្ងៃធ្វើការ ពេលព្រឹកចាប់ពីម៉ោង ៧:៣០ នាទី ដល់ម៉ោង ១១:០០ នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:៣០ នាទី ដល់ម៉ោង ១៧:០០ នាទី។

បញ្ជាក់៖ ពាក្យសុំចូលបម្រើការងារជាមន្ត្រីជាប់កិច្ចសន្យា អាចទាញយកបានតាមរយៈគេហទំព័រផ្លូវការរបស់ក្រសួងរ៉ែ និង ថាមពល (www.mme.gov.kh) ឬ តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង (www.facebook.com/MMECambodia)។

រដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

ស៊ុយ សែម

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh